**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៦ អនក្រ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ សម្រាប់កម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន - ដំណាក់កាលទី ៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងកិច្ចព្រមព្រៀងអនុវត្តកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន- ដំណាក់កាលទី ៤ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ សម្រាប់គ្រប់គ្រងកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន- ដំណាក់កាលទី ៤ ក្នុងក្របខណ្ឌនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសហព័ន្ធស្វីស ។ សមាសភាពនៃគណៈកម្មាធិការនេះមានដូចតទៅ ÷

www.pheakdeylaw.com

១-តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធាន

២-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៤-តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម សមាជិក

៥-តំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមាជិក

៦-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៧-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៨-តំណាងក្រសួងកិច្ចការនារី សមាជិក

៩-តំណាងក្រសួងពាណិជ្ជកម្ម សមាជិក

១០-តំណាងក្រសួងទេសចរណ៍ សមាជិក

១១-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១២-អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ឬតំណាង សមាជិក

១៣-អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ឬតំណាង សមាជិក

១៤-អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ឬតំណាង សមាជិក

១៥-អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ឬតំណាង សមាជិក

១៦-តំណាងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ សមាជិក

១៧-តំណាងទីភ្នាក់ងារសហប្រតិបត្តិការស្វីស សមាជិក

១៨-នាយកគ្រប់គ្រងកម្មវិធី សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការនេះត្រូវកំណត់ដោយប្រកាសរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ២.-**

គណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ សម្រាប់គ្រប់គ្រងកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន-ដំណាក់កាលទី ៤ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធី ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ, ផ្តល់ការណែនាំកម្រិតគោលនយោបាយ និងតម្រង់ទិសការអនុវត្តកម្មវិធី ដើម្បីធានាសង្គតិភាពជាមួយគោលនយោបាយ, យុទ្ធសាស្ត្រ និងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងការកែទម្រង់ស្នូលដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនេះ

-ពិនិត្យ និងអនុម័តផែនការ និងថវិកាប្រចាំឆ្នាំរបស់កម្មវិធី និងសម្របសម្រួលការវិភាជ និងការប្រើប្រាស់ថវិកាបដិភាគរបស់រាជរដ្ឋាភិបាល

-តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តកម្មវិធី ព្រមទាំងពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំ, ពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិរបស់កម្មវិធី រួមទាំងរបាយការណ៍ហិរញ្ញវត្ថុ

www.pheakdeylaw.com

-ចែករំលែកបទពិសោធន៍ និងឧត្តមានុវត្តន៍នៃការអនុវត្តកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន-ដំណាក់កាលទី ៤ ដល់បណ្តាតួអង្គអភិវឌ្ឍន៍ និង

-បំពេញការងារផ្សេងទៀត តាមការកំណត់របស់ប្រធានគណៈកម្មាធិការ ឬរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៣.-**

គណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិត្រូវប្រជុំសាមញ្ញ ១ ដង ក្នុង ១ ឆ្នាំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មាធិការអាចកោះប្រជុំវិសាមញ្ញ តាមការចាំបាច់ ។ ប្រធានគណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង ឬស្ថាប័នដទៃទៀត ចូលរួមប្រជុំ ដើម្បីជំរុញល្បឿននៃការអនុវត្តកម្មវិធី ប្រកបដោយប្រសិទ្ធភាព ។ គណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ដំណើរការការងារ ។

**ប្រការ ៤.-**

គណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន ។ លេខាធិការដ្ឋានមានទីតាំងនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយបំពេញភារកិច្ចតាមការកំណត់របស់គណៈកម្មាធិការ ។

**ប្រការ ៥.-**

រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ, អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, អភិបាលនៃគណៈអភិបាលខេត្តសៀមរាប, បន្ទាយមានជ័យ, ឧត្តរមានជ័យ និងព្រះវិហារ និងភាគីពាក់ព័ន្ធដទៃទៀត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃចន្ទ ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com